# កម្មវិធីយូនីសេហ្វ ប្រចាំប្រទេសកម្ពុជា ២០១៩ - ២០២៣



© UNICEF Cambodia/2019/Chansereypich Seng

unicef | for every child

# ទិដ្ឋភាពរួម

ជាមួយនឹងប្រជាជនមួយភាគបី មានអាយុក្រោម ១៥ឆ្នាំ ប្រទេសកម្ពុជា គឺជាប្រទេសដែលមានប្រជាជនវ័យក្មេងជាងគេមួយនៅអាស៊ីអាគ្នេយ៍។  ប្រជាជនវ័យក្មេងពោរពេញដោយភាពស្វាហាប់ និងងាយផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយនេះកំពុងត្រៀមចូលមកក្នុងកម្លាំងពលកម្ម និងមានសក្តានុពល អាចរួមចំណែកយ៉ាងធំធេងដល់ការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។

បន្ទាប់ពីទទួលបានកំណើនសេដ្ឋកិច្ចខ្ពស់រយៈពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះ នៅឆ្នាំ២០១៦ ប្រទេសកម្ពុជាបានក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និងជាប់ចំណាត់ថ្នាក់ជាប្រទេសមានសេដ្ឋកិច្ចរីកចម្រើនឆាប់រហ័សជាងគេទី៦ក្នុងពិភពលោក។ កំណើនសេដ្ឋកិច្ចបានកាត់បន្ថយអត្រាភាពក្រីក្ររបស់ប្រទេសនេះគួរឱ្យកត់សម្គាល់ ពី ៥៣,២ភាគរយ ក្នុងឆ្នាំ២០០៤ មក ១៣,៥ភាគរយ ក្នុងឆ្នាំ២០១៤។

ជារួម ប្រទេសកម្ពុជាបានសម្រេចនូវការអភិវឌ្ឍគួរឱ្យកត់សម្គាល់ក្នុងរយៈពេលមួយដ៏ខ្លី។ ចន្លោះពីឆ្នាំ២០០០ ដល់ឆ្នាំ២០១៤ អត្រាមរណភាពទារក និងកុមារអាយុក្រោមប្រាំឆ្នាំបានថយចុះជាង ៧០ ភាគរយ ខណៈដែលអត្រាមរណភាពមាតាថយចុះយ៉ាងគំហុកពី ៤៧២ករណី មកនៅ ១៧០ករណីស្លាប់ នៅរៀងរាល់ ១០០.០០០កំណើតរស់។ ភាពល្អប្រសើរនៃសេវាថែទាំផ្ទៃពោះ និងសេវាថែទាំក្រោយសម្រាល ការពង្រីកការគ្របដណ្តប់នៃសេវាផ្តល់ថ្នាំបង្ការ និងការសម្រាលកូនដោយឆ្មបជំនាញ គឺជាកត្តាមួយចំនួនដែលនាំឱ្យមានភាពល្អប្រសើរទាំងនេះ។

ចាប់តាំងពីឆ្នាំ២០០៧ មក ចំនួនកុមារចុះឈ្មោះចូលរៀនក្នុងកម្មវិធីអប់រំកុមារតូច បានកើនឡើងជាងទ្វេដង ខណៈដែលចំនួនកុមារចុះឈ្មោះចូលរៀនក្នុងកម្រិតបឋមសិក្សាក៏មានការកើនឡើងផងដែរ ពី ៨២ភាគរយ ក្នុងឆ្នាំ១៩៩៧ មកដល់ជាង ៩៧ភាគរយ ក្នុងឆ្នាំសិក្សា២០១៧/១៨។ គម្លាតយេនឌ័រនៃការចូលរៀននៅសាលាបឋមសិក្សា និងមធ្យមសិក្សា ក៏ត្រូវបានលុបបំបាត់ភាគច្រើនផងដែរ។

ចំនួនមណ្ឌលថែទាំកុមារនៅកម្ពុជា បានថយចុះ ៣៥ភាគរយ ពី ៤០៦មណ្ឌល ក្នុងឆ្នាំ២០១៥ មកនៅ ២៦៥មណ្ឌល ក្នុងឆ្នាំ២០១៨។ បើតាមទិន្នន័យក្នុងឆ្នាំ២០១៨ មានកុមារចំនួន ៧.៦៣៤នាក់ កំពុងរស់នៅតាមមណ្ឌលថែទាំកុមារ ដោយចំនួននេះបានថយចុះប្រមាណ ៥៤ភាគរយ គិតចាប់ពីឆ្នាំ២០១៥ មក។ កុមារត្រូវបានធ្វើសមាហរណកម្មចេញពីមណ្ឌលថែទាំកុមារ មានការគ្រប់គ្រងមណ្ឌលថែទាំកុមារកាន់តែល្អប្រសើរជាងមុន ដោយប្រើប្រាស់យន្តការអធិការកិច្ចតាមប្រព័ន្ធឌីជីថល និងពុំមានការបើកមណ្ឌលថ្មីឡើយចាប់តាំងពីឆ្នាំ២០១៦ ដែលនេះជាសមិទ្ធផលគួរឱ្យកត់សម្គាល់ក្នុងប្រទេសមួយដែលកាលពីពីរបីឆ្នាំមុននេះ ចំនួនមណ្ឌលថែទាំកុមារបានកើនឡើងក្នុងកម្រិតដែលមិនអាចគ្រប់គ្រងបាន។

ខណៈដែលមានការសម្រេចបាននូវវឌ្ឍនភាពជាក់លាក់ វឌ្ឍនភាពទាំងនេះពុំត្រូវបានបែងចែកឱ្យស្មើភាពគ្នានោះឡើយ ដោយមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងរវាងតំបន់ជនបទ និងតំបន់ប្រជុំជន រវាងកុមារដែលមានពិការភាព និងកុមារដែលពុំមានពិការភាព និងរវាងគ្រួសារដែលមានជីវិតភាពធូរធារ និងគ្រួសារដែលមានជីវភាពក្រីក្រ។ បញ្ហាប្រឈមនៅតែបន្តកើតមានចំពោះកុមារ និងស្ត្រីជាច្រើននាក់នៅក្នុងប្រទេសកម្ពុជា ហើយពួកគេ អាចជួបការលំបាកខ្លាំងក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

ខណៈដែលក្នុងឆ្នាំ២០០៩ ប្រទេសកម្ពុជាបានសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ដោយបានកាត់បន្ថយភាពក្រីក្រឱ្យនៅពាក់កណ្តាល បច្ចុប្បន្ននេះមានប្រជាពលរដ្ឋ ៤,៥ លាននាក់កំពុងរស់នៅកៀកនឹងភាពក្រីក្រ ហើយពួកគេមួយភាគធំ រស់នៅតាមតំបន់ជនបទដែលងាយធ្លាក់ចូលទៅក្នុងភាពក្រីក្រវិញនៅពេលដែលពួកគេប្រឈមនឹងវិបត្តិសង្គមសេដ្ឋកិច្ច និងគ្រោះមហន្តរាយធម្មជាតិកើតឡើង។ ភាពក្រីក្រ គឺជាបាតុភូតចម្រុះដែលប៉ះពាល់លើផ្នែកជាច្រើននៃជីវិត ដូចជាសុខភាព អប់រំ និងការចូលរួមជាដើម។ ក្នុងប្រទេសកម្ពុជា ភាពក្រីក្រពហុសមាសភាគ មានការថយចុះ ប៉ុន្តែមិនថយចុះលឿនដូចភាពក្រីក្រគិតតាមប្រាក់ចំណូលនោះឡើយ។ កុមារកម្ពុជាជិតពាក់កណ្តាលនៅបន្តរស់នៅក្នុងភាពក្រីក្រពហុសមាសភាគនេះ។

ទោះបីជាមានកំណើនជារួមយ៉ាងណាក៏ដោយ ការវិភាជថវិកាសម្រាប់សេវាសង្គមនៅមិនទាន់មានចំនួនគ្រប់គ្រាន់នៅឡើយ ដែលធ្វើឱ្យកម្មវិធីសំខាន់ៗជាច្រើន ពុំបានទទួលថវិកាគាំទ្រគ្រប់គ្រាន់។ ខណៈដែលតំបន់ភាគច្រើនក្នុងប្រទេសកម្ពុជាគឺជាតំបន់ជនបទ ការពង្រីក និងការអភិវឌ្ឍទីក្រុងក៏កំពុងកើតមានឡើងយ៉ាងឆាប់រហ័សផងដែរ។ បើតាមព្យាករណ៍នៅត្រឹមឆ្នាំ២០៣០ ប្រជាជនមួយភាគបីនៃប្រទេសនឹងរស់នៅក្នុងតំបន់ប្រជុំជន។ ការខកខានពុំបានបង្កើតហេដ្ឋារចនាសម្ព័ន្ធសេវាសង្គមនៅតាមតំបន់ប្រជុំជនឱ្យស្របទៅនឹងកំណើនចំនួនប្រជាជនក្នុងតំបន់ប្រជុំជននឹងនាំឱ្យមានការកើតឡើងនូវសមាសភាគថ្មីៗនៃភាពក្រីក្រជាមិនខាន។

ការធ្វើចំណាកស្រុកកើតមានជាទូទៅនៅក្នុងប្រទេសកម្ពុជា ហើយបច្ចុប្បន្ននេះមានប្រជាពលរដ្ឋប្រមាណ ៤,២ លាននាក់ ធ្វើចំណាកស្រុកក្នុងប្រទេស ដែលក្នុងនោះ ៨,៣ ភាគរយ ជាក្មេងជំទង់អាយុចន្លោះពី ១០ ទៅ ១៩ឆ្នាំ។ អ្វីដែលជាការព្រួយបារម្ភខ្លាំងឡើងៗនោះ គឺចំនួនកុមារដែលត្រូវបានទុកចោលឱ្យជីដូនជីតាថែទាំ ដែលប្រហែលជាមិនអាចផ្តល់ការថែទាំឱ្យបានគ្រប់គ្រាន់ដល់កុមារទាំងនោះឡើយ។

ក្នុងប្រទេសកម្ពុជា ក្នុងចំណោមកុមារីកុមារាអាយុក្រោម១៨ឆ្នាំពីរនាក់ មានម្នាក់បានទទួលរងអំពើហិង្សាផ្លូវកាយ។ ម្នាក់ក្នុងចំណោមបួននាក់ បានទទួលរងអំពើហិង្សាផ្លូវចិត្ត និងមានកុមារជាច្រើននាក់ត្រូវបានគេជួញដូរបង្ខំឱ្យធ្វើការងាររស់នៅបែកពីក្រុមគ្រួសារ និងត្រូវបានគេយកទៅដាក់ឱ្យរស់នៅក្នុងមណ្ឌលថែទាំកុមារទាំងមិនចាំបាច់។ របាយការណ៍អធិការកិច្ចឆ្នាំ២០១៨ បានរកឃើញថា ក្នុងចំណោមកុមារដែលរស់នៅតាមមណ្ឌលថែទាំកុមារ មាន ៦៨ភាគរយ នៅមានឪពុក ឬម្តាយនៅរស់។

ប្រទេសកម្ពុជា បានសម្រេចនូវវឌ្ឍនភាពជាបណ្តើរៗ ប៉ុន្តែនៅពុំទាន់បានគ្រប់គ្រាន់នៅឡើយដើម្បីសម្រេចចំណុចដៅលើផ្នែកអនាម័យ និងទឹកស្អាតរបស់ខ្លួន។ បើទោះបីជាប្រព័ន្ធទឹកស្អាត និងអនាម័យមានភាពល្អប្រសើរជាងមុននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិយ៉ាងណាក៏ដោយ បច្ចុប្បន្នប្រទេសនេះ គឺជាប្រទេសដែលមានអត្រាបន្ទោរបង់ពាសវាលពាសកាលខ្ពស់ជាងគេនៅក្នុងតំបន់ ពោលគឺក្នុងចំណោមប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រជាងគេរស់នៅតំបន់ជនបទ ១០នាក់ មាន៨នាក់ នៅបន្ទោរបង់ពាសវាលពាសកាលដាក់ក្នុងប្រភពទឹក ឬកន្លែងចំហដទៃទៀត ជាជាងប្រើប្រាស់បង្គន់ឱ្យបានត្រឹមត្រូវ។ បញ្ហានេះនៅបន្តជាបញ្ហាប្រឈមដ៏សែនគ្រោះថ្នាក់ ព្រោះថាសំណល់របស់មនុស្សដែលនៅជិតផ្លូវទឹក និងផ្ទះសម្បែងបែបនេះ អាចនាំឱ្យមានការសាយភាយជំងឺយ៉ាងឆាប់រហ័សដែលធ្វើឱ្យកុមារ និងគ្រួសារទាំងមូលត្រូវប្រឈមនឹងហានិភ័យ។

ប្រជាពលរដ្ឋកម្ពុជាម្នាក់ក្នុងចំណោមប្រាំនាក់ ប្រើប្រាស់ទឹកពីប្រភពទឹកផឹក ដែលពុំត្រូវបានកែលម្អ មានន័យថាពួកគេពុំបានបែងចែកសំណល់របស់មនុស្សឱ្យនៅឆ្ងាយពីមនុស្សឡើយហើយក្នុងពេលជាមួយគ្នា ក៏មានសាលាមត្តេយ្យសិក្សាចំនួនប្រាំពីរក្នុងចំណោមសាលាបឋមសិក្សាចំនួនដប់ ពុំមានបរិក្ខារទឹកស្អាត និងអនាម័យប្រើប្រាស់។ ក្នុងចំណោមមណ្ឌលសុខភាពជនបទចំនួនពីរ មានមួយកន្លែងពុំមានទឹកគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ពេញមួយឆ្នាំឡើយ។

ស្ថិតនៅក្រោយសូចនាករសង្គមផ្សេងទៀត អត្រាកង្វះអាហារូបត្ថម្ភរបស់កុមារអាយុក្រោម៥ឆ្នាំ មានកម្រិតខ្ពស់ជាងគេនៅក្នុងតំបន់នេះ ដោយមានកុមារ ៣២ ភាគរយមានបញ្ហាក្រិសក្រិន (កម្ពស់ទាបពេកបើធៀបនឹងអាយុរបស់ពួកគេ) និង ១០ភាគរយមានបញ្ហាស្គមស្គាំង (ស្គមពេកបើធៀបនឹងកម្ពស់របស់ពួកគេ)។ កត្តាដែលបន្ទបបង្អាក់មិនឱ្យមានភាពរីកចម្រើនក្នុងសូចនាករនេះ រួមមាន ការផ្តល់អាហារមិនបានត្រឹមត្រូវ ទម្លាប់ប្រើទឹកស្អាត និងអនាម័យពុំបានល្អប្រសើរ ភាពក្រីក្រ និងការខ្វះការអប់រំរបស់ម្តាយ។ គម្លាតក៏កើតមានផងដែរនៅក្នុងផ្នែកនេះ ពោលគឺមានកុមារី និងកុមារាមកពីគ្រួសារដែលមានជីវភាពក្រីក្រជាងគេ ៤២ភាគរយដែលមានបញ្ហាក្រិះក្រិន ខណៈដែលមានកុមារតែ ១៩ ភាគរយតែប៉ុណ្ណោះមកពីគ្រួសារដែលមានជីវភាពធូរធារជាងគេដែលមានបញ្ហាក្រិសក្រិននេះ។

កុមារី និងកុមារាជាច្រើននាក់ ពុំបានសម្រេចតាមស្តង់ដាររៀនសូត្រស្របតាមអាយុរបស់ពួកគេឡើយ។ នៅកម្រិតបឋមសិក្សា កុមាររៀនថ្នាក់ទី៣ ជិត២៥ភាគរយមិនអាចសរសេរសូម្បីតែមួយពាក្យ ក្នុងតេស្តសរសេរតាមអាន។ កត្តាសំខាន់ៗដែលនាំឱ្យមានបញ្ហាទាំងនេះកើតមានឡើង រួមមាន៖ កុមារពុំបានទទួលការត្រៀមរៀបចំខ្លួនសម្រាប់ចូលរៀន ខ្វះទឹកចិត្តបន្តការរៀនសូត្រ អំពើហិង្សាលើកុមារនៅតាមសាលារៀន ដោយគ្រូបង្រៀនជាអ្នកប្រព្រឹត្តិអំពើហិង្សាបែបនេះញឹកញាប់ជាងគេ បញ្ហាហិរញ្ញវត្ថុរបស់គ្រួសារ និងការបង្រៀន និងរៀននៅមានកម្រិតទាប។ ចំនួនសិស្សច្រើនធៀបនឹងចំនួនគ្រូតិច បានដាក់ទម្ងន់បន្ថែមទៀតលើបញ្ហាទាំងនេះ។

ក្នុងឆ្នាំ២០១៩ មានកុមារប្រមាណ ១.៥៤០នាក់ ជាប់ឃុំឃាំង។ កុមារដែលមានទំនាស់ជាមួយនឹងច្បាប់ គឺជាក្រុមដែលងាយរងគ្រោះខ្លាំង ហើយប្រព័ន្ធយុត្តិធម៌ដែលពុំត្រូវបានកែសម្រួលឱ្យស្របទៅតាមតម្រូវការរបស់ពួកគេ បែរជាអាចបង្កគ្រោះថ្នាក់ដល់ពួកគេទៅវិញ។ មានការជំរុញឱ្យប្រទេសកម្ពុជាដាក់ឱ្យអនុវត្តច្បាប់ ដើម្បីការពារកុមារ និងស្ត្រី ប៉ុន្តែកម្ពុជានៅខ្វះប្រព័ន្ធការពារកុមារដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដែលជាមូលដ្ឋានសម្រាប់ដាក់ចេញនូវចក្ខុវិស័យ និងក្របខណ្ឌជាតិ ដើម្បីការពារកុមារពីគ្រោះថ្នាក់នានា។

ក្នុងរបាយការណ៍ស្តីពីគម្លាតយេនឌ័រឆ្នាំ២០១៨ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី៩៣ លើ១៤៩ បើទោះជាកម្ពុជាសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយគម្លាតយេនឌ័រក្នុងវិស័យអប់រំ សុខាភិបាល និងការរស់រានយ៉ាងណាក៏ដោយ។ វឌ្ឍនភាពក្នុងល្បឿនមួយយឺត ដើម្បីឆ្ពោះទៅសម្រេចឱ្យបាននូវសមធម៌យេនឌ័រក្នុងការចូលរួមក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គម កើតឡើងភាគច្រើនដោយសារតែបទដ្ឋានសង្គមវប្បធម៌ ឥរិយាបថ និងការអនុវត្តនានា។

ជាប់ចំណាត់ថ្នាក់ជាប្រទេសដែលប្រឈមនឹងហានិភ័យខ្ពស់ជាងគេទី៨ ក្នុងពិភពលោក ដោយសារតែការប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់ និងសមត្ថភាពទប់ទល់នឹងគ្រោះធម្មជាតិនៅមានកម្រិត ប្រទេសកម្ពុជាកាន់តែងាយរងគ្រោះដោយសារតែការប្រែប្រួលអាកាសធាតុ។ ភាពងាយរងគ្រោះទាំងនេះ ធ្វើឱ្យប៉ះពាល់ដល់សមិទ្ធផលនៃការអភិវឌ្ឍរបស់ប្រទេស រាប់បញ្ចូលទាំងការកាត់បន្ថយភាពក្រីក្រផងដែរ។

កុមារដែលមានពិការភាព គឺជាក្រុមកុមារ "ដែលគេពុំសូវយកចិត្តទុកដាក់" ក្នុងកម្មវិធីអភិវឌ្ឍន៍ទូទៅ ដែលបញ្ហានេះរឹតតែធ្ងន់ធ្ងរទៅទៀត ដោយសារកង្វះទិន្នន័យដែលមានគុណភាពអំពីក្រុមកុមារទាំងនេះ និងអំពីតម្រូវការរបស់ពួកគេ។

ប្រសិនបើពុំមានការឆ្លើយតបចំពោះបញ្ហាវិសមភាពបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជានោះទេ បញ្ហាទាំងនេះនឹងត្រូវផ្ទេរពីជំនាន់មួយទៅជំនាន់មួយទៀត ជាវដ្តដែលបង្កនូវផលវិបាកអវិជ្ជមានផ្នែកសេដ្ឋកិច្ច នយោបាយ និងសង្គមជាទូទៅក្នុងប្រទេសទាំងមូល។

យូនីសេហ្វ សហការជាមួយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសង្គមស៊ីវិល ដើម្បីឆ្លើយតបចំពោះបញ្ហាវិសមភាពទាំងនេះ ដើម្បីឱ្យកុមារជាពិសេសកុមារដែលងាយរងគ្រោះជាងគេ អាចទទួលបានការថែទាំ និងការការពារ និងអាចឈានទៅសម្រេចសក្តានុពលពេញលេញរបស់ពួកគេ។

ជាមួយនឹងការផ្តោតការយកចិត្តទុកដាក់លើគុណភាព ការបង្កភាពងាយស្រួលដល់ការទទួលបានសេវា សមធម៌ បរិយាបន្ន និងភាពពាក់ព័ន្ធ សកម្មភាពរបស់យើងត្រូវបានបែងចែកជាកម្មវិធី ដូចដែលត្រូវបានរៀបរាប់ក្នុងកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការរវាងយូនីសេហ្វ ជាមួយរាជរដ្ឋាភិបាលកម្ពុជា (កម្មវិធីប្រចាំប្រទេស ២០១៩-២០២៣)។ ផ្អែកតាមមេរៀនដែលទទួលបានពីកម្មវិធីប្រចាំប្រទេស ២០១៦-២០១៨ ចក្ខុវិស័យរបស់យើង គឺរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ជាតិ ដើម្បីឱ្យកុមារី និងកុមារាទាំងអស់ ជាពិសេសកុមារដែលជួបការលំបាកជាងគេអាចសម្រេចបានជាបណ្តើរៗនូវសិទ្ធិជាមូលដ្ឋានរបស់ពួកគេ ដូចជាសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការថែទាំ សិទ្ធិទទួលបានការការពារ សិទ្ធិទទួលបានការអភិវឌ្ឍ និងសិទ្ធិចូលរួម ដើម្បីឈានទៅសម្រេចសក្តានុពលពេញលេញរបស់ពួកគេ។


© UNICEF Cambodia/2018/FANI LLAURADO

## របាយការណ៍ស្ដីពី
## គម្លាតយេនឌ័រ ឆ្នាំ
## ២០១៨






ប្រទេសកម្ពុជាជាប់
ចំណាត់ថ្នាក់ទី៩៣
ក្នុងចំណោម១៤៩
ប្រទេស

---

**ការវិនិយោគលើកុមារ មិនគ្រាន់តែជា
ផ្នែកដ៏សំខាន់ប៉ុណ្ណោះទេ ប៉ុន្តែវាគឺជា
ស្នូលនៃការអភិវឌ្ឍមនុស្ស។**

---

# ព័ត៌មានសង្ខេបអំពីកុមារនៅកម្ពុជា




ទារក ៣៥នាក់ ក្នុងចំណោម ១.០០០នាក់ បាត់បង់ជីវិតមុនពួកគេមានអាយុ ៥ឆ្នាំ

កុមារ ៣២ ភាគរយ មានបញ្ហាក្រិសក្រិន និង ១០ ភាគរយមានក្រិសក្រិនធ្ងន់ធ្ងរ










ប្រជាពលរដ្ឋកម្ពុជាដែលមានជីវភាពក្រីក្រជាងគេរស់នៅជនបទ ៨ នាក់ក្នុងចំណោម ១០ នាក់ នៅតែបន្ទោរបង់ពាសវាលពាសកាល

មណ្ឌលសុខភាពជនបទ ១ ក្នុងចំណោមមណ្ឌលសុខភាព ជនបទចំនួន ២ ពុំមានទឹកគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ ពេញមួយឆ្នាំឡើយ







កុមារ ៩៣ភាគរយ បានចុះឈ្មោះចូលរៀននៅសាលា បឋមសិក្សាក្នុងឆ្នាំសិក្សា ២០១៦/១៧




ឈានដល់អាយុ ១៧ឆ្នាំ សិស្សវ័យជំទង់ចំនួន ៥៥%
បោះបង់ចោលការសិក្សា

ក្នុងចំណោមកុមារ ២នាក់ មាន ១នាក់ បានទទួលរង
ការវាយដំធ្ងន់ធ្ងរ







កុមារចំនួន ៧.៦៣៤នាក់ បានរស់នៅក្នុងមណ្ឌលថែទាំ
ក្នុងឆ្នាំ២០១៨

កុមារជិត ៤៩ភាគរយ រស់នៅក្នុងភាពក្រីក្រពហុសមាសភាគ
ពោលគឺពួកគេជួបនឹងការលំបាកយ៉ាងហោចណាស់ចំនួន
បីប្រភេទ







ក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាប្រមាណ ១៦លាននាក់
មានប្រមាណ ៤,៥ លាននាក់ នៅបន្តមានជីវភាពកៀក
នឹងភាពក្រីក្រ។

# យូនីសេហ្វនៅកម្ពុជា

យូនីសេហ្វ ចាប់ផ្តើមបំពេញការងាររបស់ខ្លួននៅកម្ពុជាក្នុងឆ្នាំ១៩៥២ និងបានបើកការិយាល័យប្រចាំប្រទេសដំបូងក្នុងឆ្នាំ ១៩៧៣ ក្នុងពេលដែលសង្គ្រាមស៊ីវិលកំពុងកើតឡើងដល់កម្រិតកំពូលនៅក្នុងប្រទេសនេះ។ នៅពេលនោះ ភារកិច្ចចម្បងរបស់យូនីសេហ្វ គឺផ្តល់ជំនួយសង្គ្រោះមនុស្សធម៌ដល់កុមារដែលរងផលប៉ះពាល់ពីជម្លោះ។ យូនីសេហ្វ គឺជាអង្គការអន្តរជាតិមួយក្នុងចំណោមអង្គការអន្តរជាតិជាច្រើន ដែលត្រូវបានបណ្តេញចេញពីប្រទេសនេះក្នុងឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមចូលក្តោបក្តាប់អំណាច។

ក្រោយការដួលរលំនៃរបបនេះក្នុងឆ្នាំ ១៩៧៩ យូនីសេហ្វ ស្ថិតក្នុងចំណោមអង្គការដំបូងៗដែលបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បីផ្តល់ជំនួយក្នុងស្ថានភាពអាសន្ន។ ក្រោយត្រឡប់មកវិញ យូនីសេហ្វបានធ្វើសកម្មភាពឆ្លើយតបចំពោះបញ្ហាប្រឈមធ្ងន់ធ្ងរពាក់ព័ន្ធនឹងសេវាសុខាភិបាល អនាម័យ និងការចែកជំនួយ ដូចជាការផ្តល់ទឹកស្អាតសម្រាប់ផឹក និងការចែកសម្ភារអប់រំសំខាន់ៗដល់កុមារ ដើម្បីឱ្យពួកគេអាចវិលត្រឡប់ទៅសាលារៀនវិញ។

ស្ថិរភាពនយោបាយនៅក្នុងប្រទេសកម្ពុជា មានការកើនឡើង ជាមួយនឹងការបោះឆ្នោតបែបប្រជាធិបតេយ្យជាលើកដំបូងក្នុងឆ្នាំ ១៩៩៣ ដែលផ្តល់លទ្ធភាពឱ្យយូនីសេហ្វ អាចពង្រឹងភាពជាដៃគូរបស់ខ្លួនជាមួយនឹងរាជរដ្ឋាភិបាល។

យូនីសេហ្វ បំពេញភារកិច្ចក្រោមក្របខ័ណ្ឌនៃអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិកុមារ។ ជាមួយនឹងបទពិសោធជាង៧០ឆ្នាំ យូនីសេហ្វ គឺជាអង្គការតែមួយគត់ដែលត្រូវបានលើកឡើងចំឈ្មោះក្នុងអនុសញ្ញានេះ ថាជាប្រភពអ្នកជំនាញសម្រាប់ផ្តល់ជំនួយ និងដំបូន្មាននានា។

ហៅកាត់ថា CRC កិច្ចព្រមព្រៀងកម្រិតសកលនេះ លើកឡើងពីតម្រូវការកុមារដើម្បីរស់រាន និងអភិវឌ្ឍ និងដើម្បីអាចសម្រេចបាននូវសក្តានុពលពេញលេញបំផុតរបស់ពួកគេនៅក្នុងពិភពលោក។ អនុសញ្ញានេះ គឺជាសេចក្តីថ្លែងការណ៍ពេញលេញបំផុតអំពីសិទ្ធិកុមារដែលមិនធ្លាប់មានពីមុន និងជាសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលបានទទួលការផ្តល់សច្ចាប័នទូលំទូលាយជាងគេក្នុងប្រវត្តិសាស្ត្រ។

អនុសញ្ញាស្តីពីសិទ្ធិកុមារ បានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងច្រើន នូវរបៀបនៃការយកចិត្តទុកដាក់លើកុមារ ពីមនុស្សអសកម្មដែលចាំទទួលការថែទាំ និងជំនួយសប្បុរសធម៌ ទៅជាម្ចាស់សិទ្ធិ។ ការប្តេជ្ញាចិត្តជាផ្លូវការរបស់ប្រទេសកម្ពុជា ក្នុងការបង្កើតនូវឱកាសកាន់តែល្អប្រសើរ និងបង្កើតនូវលក្ខខណ្ឌ ដើម្បីបង្កើនសុវត្ថិភាព លើកកម្ពស់សុខភាព និងជីវភាពរស់នៅរបស់កុមារ ត្រូវបានពង្រឹងបន្ថែមតាមរយៈការបញ្ចូលអនុសញ្ញានេះទៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៣។

ការិយាល័យកណ្តាលរបស់យូនីសេហ្វប្រចាំប្រទេសកម្ពុជា មានមូលដ្ឋាននៅទីក្រុងភ្នំពេញ។ ការិយាល័យនេះ ទទួលបានការគាំទ្រពីការិយាល័យប្រចាំតំបន់ ចំនួនពីរ នៅក្នុងខេត្តក្រចេះ និងខេត្តសៀមរាប។ ខណៈពេលដែលប្រតិបត្តិការរបស់អង្គការនេះ លាតសន្ធឹងទូទាំងផ្ទៃប្រទេស យូនីសេហ្វផ្តោតការយកចិត្តទុកដាក់លើខេត្តទាំងឡាយណាដែលនៅមានការខ្វះខាតខ្លាំងជាងគេ និងនៅមានសូចនាករអភិវឌ្ឍន៍កុមារអន់ខ្សោយជាងគេ ដែលជាការធានាឱ្យមានការប្រើប្រាស់អតិក្រមប្រកបដោយសមធម៌ ដើម្បីឱ្យស្ត្រី និងកុមារអាចរស់នៅបានល្អប្រសើរ។

យូនីសេហ្វ ទទួលបានការគាំទ្រពីការរួមភាគទានស្ម័គ្រចិត្តពីអ្នកផ្តល់ជំនួយ រដ្ឋាភិបាល សប្បុរសជន វិស័យឯកជន និងគណៈកម្មាធិការជាតិយូនីសេហ្វ ដែលជាបណ្តាញអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលបំពេញការងារប្រកបដោយឯករាជ្យភាព និងធ្វើការអង្គាសប្រាក់ពីវិស័យឯកជន ដើម្បីបុព្វហេតុលើកកម្ពស់សិទ្ធិកុមារ។



© UNICEF Cambodia/2018/Victoria Laroche Creux

# សមិទ្ធផលសំខាន់ៗ សម្រាប់ស្ត្រី និងកុមារ



តាមរយៈកិច្ចសហការរវាងរាជរដ្ឋាភិបាលកម្ពុជា យូនីសេហ្វ អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងដៃគូអភិវឌ្ឍន៍ វឌ្ឍនភាពជាច្រើន ក្នុងវិស័យអភិវឌ្ឍន៍សំខាន់ៗសម្រាប់កុមារត្រូវបានអនុវត្តសម្រេចបានគួរឱ្យកត់សម្គាល់។

សមិទ្ធផលមួយក្នុងចំណោមសមិទ្ធផលគួរឱ្យកត់សម្គាល់ជាងគេ គិតរហូតមកដល់បច្ចុប្បន្ន គឺការថយចុះយ៉ាងគំហុកនូវអត្រាមរណភាពមាតាពី៤៧២ករណីក្នុង១០០.០០០កំណើតរស់ក្នុងឆ្នាំ២០០០ មកនៅ១៧០ករណីក្នុង១០០.០០០កំណើតរស់ក្នុងឆ្នាំ ២០១៤។ សមិទ្ធផលដែលសម្រេចបាននេះ អាចកើតឡើងបានដោយសារភាពល្អប្រសើរនៃសេវាថែទាំផ្ទៃពោះ និងការកើនឡើងនូវចំនួនកុមារដែលត្រូវបានសម្រាលដោយឆ្មបដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ នៅតាមមណ្ឌលសុខភាព។

ក្នុងរយៈពេលដូចគ្នានេះដែរ ប្រទេសកម្ពុជា បានសម្រេចនូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការលើកកម្ពស់សុខភាពកុមារ។ អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ ថយចុះពី ១២៤ករណី មកនៅត្រឹម៣៥ករណីក្នុង១.០០០កំណើតរស់។ ភាពល្អប្រសើរនៃសេវាថែទាំក្រោយសម្រាលទារកទើបកើត និងការពង្រីកការគ្របដណ្តប់នៃសេវាផ្តល់ថ្នាំបង្ការ គឺជាកត្តាមួយចំនួន ក្នុងចំណោមកត្តានានា ដែលជំរុញឱ្យមានភាពល្អប្រសើរបែបនេះ។

ទឹកស្អាតសម្រាប់ផឹក និងសេវាអនាម័យដែលត្រូវបានកែលម្អ គឺជាកត្តារួមចំណែកលើកកម្ពស់ភាពរស់រានរបស់កុមារនៅក្នុងឆ្នាំដំបូងៗនៃជីវិត។ ភាគរយគ្រួសារដែលទទួលបានប្រភពទឹកដែលត្រូវបានកែលម្អ និងមានការញែកលាមកមនុស្ស មិនឱ្យប៉ះពាល់ជាមួយនឹងមនុស្ស កើនឡើងពី២២ភាគរយ ក្នុងឆ្នាំ១៩៩០ ដល់ ៧០ភាគរយ ក្នុងឆ្នាំ២០១៧ ខណៈពេលដែលការប្រើប្រាស់បង្គន់ដែលត្រូវបានកែលម្អ បានកើនឡើងពី៤៦,៨ភាគរយក្នុងឆ្នាំ២០០៨ រហូតដល់៥៨ភាគរយ ក្នុងឆ្នាំ២០១៤។

ប្រទេសកម្ពុជាសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការផ្តល់ការអប់រំដល់កុមារ។ កុមារកម្ពុជាកាន់តែច្រើននាក់ កំពុងរៀននៅក្នុងសាលារៀន ជាងពេលណាៗទាំងអស់។ ចំនួនកុមារដែលបានចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា កើនឡើងពី៨២ភាគរយក្នុងឆ្នាំ១៩៩៧ ដល់ ៩៧,៨ភាគរយ ក្នុងឆ្នាំសិក្សា២០១៧/១៨ ខណៈពេលដែលការចុះឈ្មោះចូលរៀនក្នុងកម្មវិធីអប់រំកុមារតូច កើនឡើងទ្វេដងចាប់តាំងពីឆ្នាំ២០០៧មក។

ការកើនឡើងនូវចំនួនកុមាររស់នៅតាមមណ្ឌលថែទាំកុមារពី៦.២៥៤នាក់ក្នុងឆ្នាំ២០០៥ រហូតដល់១៦.៥៧៩នាក់ក្នុងឆ្នាំ២០១៥ បានទទួលការឆ្លើយតបតាមរយៈគំនិតផ្តួចផ្តើមវិជ្ជមានជាច្រើនដូចជា ការសិក្សាកំណត់ពីទីតាំងមណ្ឌលថែទាំកុមារ ការពង្រឹងការចុះ ធ្វើអធិការកិច្ច ការអនុវត្តបទដ្ឋានអប្បបរមា និងការអនុវត្តផែនការសកម្មភាពសម្រាប់ការពង្រឹងការថែទាំកុមារជាដើម។ ផែនការនេះបញ្ចូលការធ្វើសមាហរណកម្មកុមារពីមណ្ឌលថែទាំកុមារទៅក្នុងគ្រួសារ និងសហគមន៍របស់ពួកគេ ហើយជាលទ្ធផល មានកុមារចំនួន ៧.៦៣៨នាក់ ត្រូវបានរាយការណ៍ថាកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារពោលគឺថយចុះប្រមាណ ៥៤ភាគរយ ចាប់តាំងពីឆ្នាំ២០១៥មក។ ក្នុងឆ្នាំ២០១៤ កុមារកម្ពុជាភាគច្រើន (៨៩ភាគរយ) រស់នៅជាមួយនឹងឪពុកម្តាយយ៉ាងហោចណាស់ម្នាក់ ហើយចាប់តាំងពីឆ្នាំ២០១៦មក ពុំមានការបើកមណ្ឌលថែទាំកុមារថ្មីឡើយ។ សមិទ្ធផលទាំងនេះគួបផ្សំនឹងការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ធ្វើអធិការកិច្ច គឺជាសញ្ញាដ៏ប្រសើរដើម្បីឈានទៅកាត់បន្ថយចំនួនកុមារដែលរស់នៅខាងក្រៅការថែទាំតាមគ្រួសារ ដែលនាំឱ្យពួកគេកាន់ទទួលបានសុវត្ថិភាព និងការទំនុកបម្រុង។

កម្មវិធីការពារកុមារដូចជា ការដាក់វិន័យបែបវិជ្ជមាន ការចិញ្ចឹមបីបាច់កូនតាមបែបវិជ្ជមាន និងកម្មវិធី **PROTECT កម្ពុជា** ជាដើម កំពុងត្រូវបានអនុវត្ត ដើម្បីការពារកុមារពីការដាក់វិន័យតាមបែបហិង្សា និងការរស់នៅបែកចាក់ពីក្រុមគ្រួសាររបស់ពួកគេ។

ក្នុងឆ្នាំ ២០១៧ ប្រទេសកម្ពុជាបានប្រកាសដាក់ឱ្យអនុវត្តនូវផែនការសកម្មភាពទីមួយ ដើម្បីឆ្លើយតបចំពោះរាល់ទម្រង់ទាំងអស់នៃអំពើហិង្សាលើកុមារ ហើយស្របពេលជាមួយគ្នា ក៏កំពុងរៀបចំអន្តរាគមន៍សម្រាប់អនុវត្តក្នុងខេត្តរតនគិរីដើម្បីទប់ស្កាត់ការរៀបអាពាហ៍ពិពាហ៍របស់កុមារ និងការមានផ្ទៃពោះរបស់ក្មេងជំទង់។ ការបន្តបង្កើនការយល់ដឹង និងការផ្សព្វផ្សាយសារអប់រំស្តីពីការទប់ស្កាត់អំពើហិង្សាកំពុងត្រូវបានធ្វើឡើងតាមរយៈការកសាងភាពជាដៃគូជាមួយនឹងស្ថាប័នសាសនា ការសាកល្បងរបៀបដាក់វិន័យតាមបែបវិជ្ជមាននៅតាមសាលារៀននិងការអភិវឌ្ឍធនធាន សម្រាប់ប្រើប្រាស់ក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ។

នៅក្នុងប្រទេសកម្ពុជា ក៏មានការជម្រុញឱ្យអនុវត្តច្បាប់ ដើម្បីផ្តល់ការការពារដល់កុមារ និងស្ត្រីផងដែរ។ ច្បាប់យុត្តិធម៌អនីតិជនថ្មី ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០១៦ និងការបន្តរៀបចំផែនការយុទ្ធសាស្រ្ត និងផែនការប្រតិបត្តិរយៈពេលបីឆ្នាំ នឹងឆ្លើយតបចំពោះកំណើនចំនួនយុវជនដែលនៅជាប់ពន្ធនាគារ ក៏ដូចជារួមចំណែកបង្កើតនូវយន្តការសម្រាប់ប្រមូលទិន្នន័យ និងរាយការណ៍កាន់តែល្អប្រសើរជាងមុន។

ក្រោយសម្រេចបានកំណើនសេដ្ឋកិច្ចកម្រិតខ្ពស់ រយៈពេលជាងពីរទសវត្សរ៍រួចមកប្រទេសកម្ពុជាបានក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៦ ជាមួយនឹងចំណូលជាតិសរុបក្នុងប្រជាជនម្នាក់ កើនឡើងរហូតដល់ ១.០៧០ដុល្លារ។ ចន្លោះពីឆ្នាំ១៩៩០ ដល់២០១៧ សន្ទស្សន៍អភិវឌ្ឍន៍មនុស្សរបស់ប្រទេសកម្ពុជា ដែលជារង្វាស់សមិទ្ធផលផ្នែកអភិវឌ្ឍន៍មនុស្សគិតជាមធ្យម កើនឡើងជិត៦០ភាគរយ ពី០,៣៦៤ ដល់ ០,៥៨២។ ក្នុងឆ្នាំ២០០៩ ប្រទេសកម្ពុជាបានសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ដោយបានកាត់បន្ថយភាពក្រីក្រចំនួនពាក់កណ្តាល និងជាប់ចំណាត់ថ្នាក់ជាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនឆាប់រហ័សជាងគេទី៦ក្នុងពិភពលោក។

ក្នុងឆ្នាំ២០១៧ រដ្ឋាភិបាលបានអនុម័តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមថ្មី ជាមួយនឹងការដាក់ចេញនូវកម្មវិធីគាំពារសង្គមសំខាន់ៗមួយចំនួនដូចជា កម្មវិធីផ្ទេរសាច់ប្រាក់ដល់កុមារ និងស្ត្រីដែលមានផ្ទៃពោះ កម្មវិធីអាហារូបករណ៍កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភដល់ជនដែលមានពិការភាព។ លើសពីនេះ ក៏មានការរៀបចំផែនទីបង្ហាញផ្លូវ ដើម្បីពង្រីកការអនុវត្តកម្មវិធីទាំងនេះផងដែរ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ប្រទេសកម្ពុជា បានសម្រេចនូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដើម្បីកុមារ ប៉ុន្តែបើទោះបីជាវឌ្ឍនភាពទាំងនេះ ស្តែងចេញឱ្យឃើញជារូបភាពជាក់ស្តែងយ៉ាងណាក៏ដោយ ក៏វឌ្ឍនភាពទាំងនេះមិនស្របនឹងការណ៍អភិវឌ្ឍន៍សហស្សវត្សរ៍នៃការមិនទុកនរណាម្នាក់ចោលឡើយ។ ខណៈពេលដែលយើងធ្វើការអបអរសាទរជោគជ័យទាំងនេះ យើងក៏ត្រូវបានក្រើនរំឭកផងដែរថា នៅបន្តមានបញ្ហាប្រឈមចំពោះមុខមួយចំនួន ដែលត្រូវដោះស្រាយ ដើម្បីធានាយ៉ាងណាឱ្យកុមារអាចទទួលបានសិទ្ធិ និងអាចសម្រេចសក្តានុពលពេញលេញក្នុងជីវិតរបស់ពួកគេ។

# កម្មវិធីប្រចាំប្រទេសរបស់យូនីសេហ្វ

យូនីសេហ្វ គាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់ការអភិវឌ្ឍកុមារប្រកដោយសុខភាពល្អ ការពារសិទ្ធិរបស់ពួកគេ និងជួយឱ្យពួកគេសម្រេចសក្តានុពលរបស់ខ្លួនចាប់ពីវ័យកុមារតូច រហូតដល់វ័យជំទង់។

យូនីសេហ្វ បានឈានដល់សករាជថ្មីនៃកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលដោយផ្អែកលើភាពជោគជ័យ ដែលសម្រេចបានក្នុងកម្មវិធីប្រចាំប្រទេសឆ្នាំ២០១៦ - ២០១៨ កន្លងមក។ នេះគឺជាឱកាសមួយដ៏សំខាន់ សម្រាប់យូនីសេហ្វ ដើម្បីផ្តល់ការគាំទ្រដល់ប្រទេសកម្ពុជា ស្របពេលដែលប្រទេសនេះទើបតែនឹងធ្វើអន្តរកាលក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។

ការបន្តកិច្ចសហប្រតិបត្តិការរបស់យូនីសេហ្វជាមួយរាជរដ្ឋាភិបាល ត្រូវបានដាក់ចេញក្នុងកម្មវិធីប្រចាំប្រទេស ២០១៩ - ២០២៣ ស្របតាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩ - ២០២៣ និងក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍សហប្រជាជាតិ។

ជាមួយនឹងការដាក់ចេញនូវកម្មវិធីប្រចាំប្រទេស ២០១៩–២០២៣ យូនីសេហ្វបានបន្តកិច្ចសន្យារបស់ខ្លួន ដើម្បីរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងក្នុងប្រទេសកម្ពុជា ដើម្បីឱ្យកុមារី និងកុមារាទាំងអស់ ជាពិសេសកុមារដែលងាយរងគ្រោះ និងជួបការលំបាកជាងគេ អាចទទួលបានសិទ្ធិរបស់ពួកគេជាបណ្តើរៗ ដូចជាសិទ្ធិរស់រាន សិទ្ធិទទួលបានការថែទាំសិទ្ធិទទួលបានការការពារ និងសិទ្ធិចូលរួម និងអភិវឌ្ឍពេញសក្តានុពលរបស់ពួកគេជាដើម។

នៅក្នុងកិច្ចសហការជាមួយរាជរដ្ឋាភិបាល យូនីសេហ្វជំរុញឱ្យមានការវិនិយោគ និងការដាក់ចេញនូវគោលនយោបាយសាធារណៈ ផ្តោតលើកុមារតូច និងក្មេងជំទង់ដើម្បីលើកកម្ពស់ធនធានមនុស្សរបស់ប្រទេសកម្ពុជា ដែលជាមូលដ្ឋានគ្រឹះ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ យើងផ្តោតការយកចិត្តទុកដាក់ជាពិសេសលើក្មេងជំទង់ តាមរយៈការធ្វើការងារជាមួយនឹងពួកគេ និងដើម្បីពួកគេ។ ការប្រយុទ្ធប្រឆាំងនឹងការរៀបអាពាហ៍ពិពាហ៍របស់កុមារ និងអំពើហិង្សាលើកុមារ ហើយស្របពេលជាមួយគ្នា លើកកម្ពស់បំណិនជីវិត យុត្តិធម៌អនីតិជនកុមារមេត្រី ការគ្រប់គ្រងអនាម័យពេលមករដូវប្រកបដោយសុវត្ថិភាព និងការបញ្ចូលកុមារដែលបាត់បង់ឱកាស គឺជាស្នូលនៃការងាររបស់យើង ដើម្បីកសាងអនាគតឱ្យកាន់តែប្រសើរ និងរឹងមាំសម្រាប់កុមារកម្ពុជា។

រាជរដ្ឋាភិបាល ជាអ្នកដឹកនាំកិច្ចសហប្រតិបត្តិការនេះ និងជាដៃគូចម្បងរបស់យូនីសេហ្វ។ យើងសហការជាមួយនឹងស្ថាប័នរដ្ឋាភិបាលនៅគ្រប់កម្រិតថ្នាក់ទាំងអស់ ចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន។ ដៃគូរបស់យើងរួមមានសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល អង្គការតាមសហគមន៍ វិស័យឯកជន ប្រព័ន្ធផ្សព្វផ្សាយទីភ្នាក់ងារសហប្រជាជាតិ និងអង្គការអន្តរជាតិដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។

ក្នុងវដ្តកម្មវិធីថ្មីខាងមុខនេះ យូនីសេហ្វ មានគោលបំណងពង្រឹងភាពជាដៃគូរបស់ខ្លួនជាមួយនឹងស្ថាប័នសិក្សាស្រាវជ្រាវ គ្រឹះស្ថានបណ្តុះបណ្តាល វិស័យឯកជន និងស្ថាប័នដែលតំណាងឱ្យកុមារដែលត្រូវបានគេផាត់ចេញ ដើម្បីឱ្យតួអង្គពាក់ព័ន្ធទាំងអស់ដែលចូលរួមក្នុងសកម្មភាពទាំងនេះ អាចមានជំនាញសមត្ថភាព និងធនធានច្រើនបំផុតដល់កម្រិតអតិបរមា។

ដើម្បីឆ្លើយតបចំពោះបញ្ហាខ្វះខាតច្រើនមុខដែលកុមារកំពុងជួបប្រទះ យើងបែងចែកការងាររបស់យើងជា ៥កម្មវិធី ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នាដូចជា៖ សុខភាព និងអាហារូបត្ថម្ភ អនាម័យ និងទឹកស្អាត អប់រំ ការការពារកុមារ និងគោលនយោបាយ និងហិរញ្ញប្បទានសាធារណៈដើម្បីកុមារជាដើម។ បញ្ហាអន្តរវិស័យ ដូចជាការអភិវឌ្ឍកុមារតូច ក្មេងជំទង់ សមភាពយេនឌ័រ សកម្មភាពមនុស្សធម៌ ពិការភាព ការប្រាស្រ័យទាក់ទងដើម្បីអភិវឌ្ឍន៍ ភាពក្រីក្រក្នុងទីក្រុង និងចំណាកស្រុក ជួយភ្ជាប់សមាសភាគផ្សេងៗនៃកម្មវិធីទាំងនេះជាមួយគ្នា។




កម្មវិធីចំនួន៥នៅក្នុងកម្មវិធីប្រចាំប្រទេសឆ្នាំ២០១៩-២០២៣ មានលក្ខណៈស្របគ្នាជាមួយនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដូចបង្ហាញជូនខាងក្រោម៖




យូនីសេហ្វ ប្តេជ្ញាចូលរួមគាំទ្រដើម្បីឈានទៅរកការសម្រេចបានដោយជោគជ័យនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជា។ យើងធ្វើការជាមួយដៃគូដោយផ្តោតការយកចិត្តទុកដាក់ទាំងស្រុងលើកុមារនៅក្នុងរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងតាមដានឲ្យប្រាកដថាគោលដៅទាំងអស់ពិតជាផ្តល់លទ្ធផលដល់កុមារគ្រប់រូបក្នុងច្រើនជំនាន់ទៅមុខ។ នៅក្នុងសេចក្តីពិពណ៌នាអំពីកម្មវិធីរបស់យើងនៅទំព័រខាងមុខ ស្លាកសញ្ញានៃគោលដៅប្រកបដោយចីរភាពត្រូវបានដាក់នៅតាមកម្មវិធីពាក់ព័ន្ធនីមួយៗ។

# សុខភាព និងអាហារូបត្ថម្ភ

**ពុំមានកុមារ ឬម្តាយណាម្នាក់គួរទទួលរងការឈឺចាប់ ឬបាត់បង់ជីវិតដោយសារមូលហេតុដែលអាចបង្ការបាននោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ នេះគឺជាស្ថានភាពដែលនៅកើតមានក្នុងប្រទេសកម្ពុជាជារៀងរាល់ឆ្នាំ។**

ករណីបាត់បង់ជីវិតទាំងនេះ អាចដោយសារតែស្ត្រីពុំទទួលបានការថែទាំសមស្របក្នុងអំឡុងពេលមានផ្ទៃពោះ ឬដោយសារតែទារកពុំបានទទួលការថែទាំក្រោយសម្រាល ឬអាហារូបត្ថម្ភសមស្របក្នុងខែដំបូងៗនៃជីវិតរបស់ពួកគេ។

កម្មវិធីសុខភាព និងអាហារូបត្ថម្ភ ផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់ការទទួលបានសេវាសុខភាព និងអាហារូបត្ថម្ភឱ្យបានគ្រប់គ្រាន់ ប្រកបដោយសមធម៌ និរន្តរភាព បរិយាបន្ន ក្នុងតម្លៃមួយសមស្រប ចាប់ពីពេលសម្រាលរហូតដល់វ័យជំទង់។ សេវាទាំងនេះមានឥទ្ធិពលយ៉ាងខ្លាំងលើលទ្ធភាពរស់រាន អភិវឌ្ឍន៍ សិក្សារៀនសូត្រ និងការងើបចេញពីភាពក្រីក្ររបស់កុមារ។ ការយកចិត្តទុកដាក់ត្រូវបានផ្តោតលើស្ត្រីមានផ្ទៃពោះ ម្តាយ ទារកទើបកើត កុមារអាយុក្រោម៥ឆ្នាំ និងក្មេងជំទង់ ជាពិសេសនៅខេត្តភាគឦសាននៃប្រទេសកម្ពុជា ដែលជាខេត្តមិនសូវទទួលបានឱកាសច្រើនដូចខេត្តដទៃទៀត។

យូនីសេហ្វ បន្តសហការជាមួយរាជរដ្ឋាភិបាល ដើម្បីឆ្លើយតបចំពោះបញ្ហាកង្វះគោលនយោបាយ និងថវិកា ប្រមូល និងប្រើប្រាស់ទិន្នន័យប្រកបដោយប្រសិទ្ធភាព ជំរុញឱ្យមានការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល និងធ្វើការផ្លាស់ប្តូរការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការការពារកុមារ សុខភាព និងការអប់រំ។ អាហារូបត្ថម្ភ គឺជាអាទិភាព ហើយ យូនីសេហ្វខិតខំជំរុញការផ្សព្វផ្សាយផលិតផលអាហារូបត្ថម្ភដែលផលិតក្នុងស្រុក ហើយក្នុងពេលជាមួយគ្នា គាំទ្រដល់រដ្ឋាភិបាលក្នុងការដាក់ចេញនូវគោលនយោបាយស្តីពីសៀ្វងអាហារ និងសុខភាព។

SUSTAINABLE DEVELOPMENT GOALS

2 ZERO HUNGER | 3 GOOD HEALTH AND WELL-BEING | 6 CLEAN WATER AND SANITATION | 10 REDUCED INEQUALITIES | 17 PARTNERSHIPS FOR THE GOALS


© UNICEF Cambodia/2018/Antoine Raab

# អនាម័យ និងទឹកស្អាត

## ទឹកស្អាត បង្គន់អនាម័យសមស្រប និងអនាម័យខ្លួនប្រាណល្អប្រសើរ មានសារៈសំខាន់យ៉ាងខ្លាំងចំពោះការរស់រាន និងការអភិវឌ្ឍរបស់កុមារ។

ចំពោះកុមារអាយុក្រោម៥ឆ្នាំ ជំងឺឆ្លងតាមទឹក និងជំងឺពាក់ព័ន្ធជាមួយអនាម័យ គឺជាមូលហេតុនាំមុខគេ ដែលធ្វើឱ្យកុមារឈឺ និងបាត់បង់ជីវិត។ ការអប់រំកុមារអំពីសារៈសំខាន់នៃការលាងសម្អាតដៃជាមួយនឹងសាប៊ូ ទឹក និងការផ្តល់ឱ្យពួកគេនូវទឹកស្អាតសម្រាប់ផឹក និងបង្គន់អនាម័យសមស្រប គឺជាវិធីសាស្រ្តដ៏មានប្រសិទ្ធភាពបំផុត ដើម្បីជួយសង្គ្រោះជីវិតរបស់ពួកគេ និងធានាយ៉ាងណាឱ្យពួកគេអាចអភិវឌ្ឍ និងមានសុខភាពល្អ។

កម្មវិធីអនាម័យ និងទឹកស្អាត ផ្តោតការយកចិត្តទុកដាក់លើការបង្កើនការផ្តល់ហិរញ្ញប្បទាន និងការសម្របសម្រួលក្នុងវិស័យទឹកស្អាត និងអនាម័យ ដើម្បីទទួលបានលទ្ធផលល្អប្រសើរក្នុងការលើកកម្ពស់ការរស់រាន សុខភាព និងការអប់រំរបស់កុមារ។ កម្មវិធីនេះធ្វើការប្រមូល និងវិភាគទិន្នន័យសម្រាប់ប្រើប្រាស់ក្នុងការសម្រេចចិត្តអំពីកម្មវិធី បង្កើនភាពធន់នឹងអាកាសធាតុក្នុងភូមិ តាមរយៈការរៀបចំផែនការត្រៀមបង្ការ ដែលផ្តោតលើវិស័យទឹកស្អាត និងអនាម័យ និងកំណត់ពីផលិតផលអនាម័យ និងទឹកស្អាតសមស្រប មានតម្លៃសមរម្យ និងងាយស្រួលប្រើប្រាស់។

យូនីសេហ្វ ផ្តោតការយកចិត្តទុកដាក់ជាពិសេសលើកុមារដែលពុំបានទទួលសេវា និងសហគមន៍របស់ពួកគេ ដែលជារឿយៗជាសហគមន៍ក្រីក្រ ឋិតនៅក្នុងទីតាំងភូមិសាស្រ្តដែលជួបការលំបាក ឬដែលប្រជាពលរដ្ឋជួបការលំបាកក្នុងសង្គម និងរស់នៅក្នុងតំបន់ងាយប្រឈមនឹងហានិភ័យបរិស្ថាន។ ការកែលម្អទឹកស្អាត និងអនាម័យសម្រាប់កុមារក្នុងប្រទេសកម្ពុជា ទាមទារឱ្យមានការប្រើប្រាស់អភិក្រមរួម ដែលមានលក្ខណៈជាប្រព័ន្ធ និងត្រូវមានការផ្សារភ្ជាប់ទំនាក់ទំនងគ្នាក៏ដូចជាការពង្រឹងបន្ថែមឱ្យគ្នាទៅវិញទៅមក រវាងអន្តរាគមន៍ក្នុងវិស័យទឹកស្អាត និងអនាម័យ សុខភាព និងអប់រំ។ ការយកចិត្តទុកដាក់ត្រូវបានផ្តោតលើការបង្កើនលទ្ធភាពទទួលបានសេវាអនាម័យបរិស្ថាន និងអនាម័យផ្ទាល់ខ្លួននៅតាមសាលារៀនមណ្ឌលសុខភាព និងផ្ទះសម្បែង ហើយក្នុងពេលជាមួយគ្នាក៏មានការអប់រំផ្សព្វផ្សាយលើកទឹកចិត្តឱ្យប្រជាពលរដ្ឋធ្វើការផ្លាស់ប្តូរការយល់ឃើញ និងទម្លាប់ពាក់ព័ន្ធនឹងអនាម័យផ្ទាល់ខ្លួន ទឹកស្អាត និងអនាម័យបរិស្ថានផងដែរ។

SUSTAINABLE DEVELOPMENT GOALS

3 GOOD HEALTH AND WELL-BEING | 4 QUALITY EDUCATION | 6 CLEAN WATER AND SANITATION | 10 REDUCED INEQUALITIES | 17 PARTNERSHIPS FOR THE GOALS


© UNICEF Cambodia/2018/Fani Llaurado

# ការអប់រំ

**កុមារគ្រប់រូប មានសិទ្ធិរៀនសូត្រ មិនថាពួកគេស្ថិតនៅក្នុងកាលៈទេសៈណានោះទេ ហើយការផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់ការរៀនសូត្រ មានសារៈសំខាន់យ៉ាងខ្លាំងដើម្បីឱ្យកុមារអាចអភិវឌ្ឍអស់សក្តានុពលរបស់ពួកគេ។ ការអប់រំប្រកបដោយគុណភាព និង បរិយាបន្ន មានសារៈសំខាន់យ៉ាងខ្លាំងចំពោះការអភិវឌ្ឍសង្គមប្រកបដោយបរិយាបន្ន។**

កម្មវិធីអប់រំ ផ្តោតការយកចិត្តទុកដាក់លើការពង្រឹងការដឹកនាំក្នុងកម្រិតរដ្ឋាភិបាល និងនៅកម្រិតសាលារៀន ការបង្កើនគុណភាពនៃការបង្រៀន និងការកសាងនូវបរិយាកាសសាលារៀនល្អប្រសើរ ដើម្បីធានាឱ្យប្រាកដថាកុមារនឹងទៅរៀនហើយបន្តរៀន។ ក្នុងកម្មវិធីនេះមានការផ្តល់ការគាំទ្រដល់រដ្ឋាភិបាលក្នុងទម្រង់ជាការផ្តល់ការបណ្តុះបណ្តាលឯកទេសដល់គ្រូបង្រៀនផងដែរ ដើម្បីឱ្យពួកគេអាចបង្រៀនកុមារបានកាន់តែល្អប្រសើរ។ ដើម្បីធានាថាកុមារគ្រប់រូបបានរៀនសូត្រ មានការផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំ ប្រកបដោយសមធម៌ និងបរិយាបន្នសម្រាប់កុមារដែលមានពិការភាព កុមារជនជាតិភាគតិច និងកុមារដែលរស់នៅក្នុងតំបន់ក្រីក្រនៅជនបទ និងទីប្រជុំជន។

កិច្ចសហការនៅបន្តជាមួយនឹងដៃគូអន្តរជាតិ ដើម្បីពង្រឹងការរៀបចំផែនការ ការគ្រប់គ្រង និងការផ្តល់ថវិកាគាំទ្រដល់វិស័យអប់រំរបស់រដ្ឋាភិបាល។ យូនីសេហ្វផ្តោតការគាំទ្របច្ចេកទេសដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងកិច្ចខិតខំប្រឹងប្រែងកែសម្រួលកម្មវិធីសិក្សាជាតិ ដើម្បីឱ្យជំនាញនៃសតវត្សរ៍ទី២១ ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជា។

SUSTAINABLE DEVELOPMENT GOALS

4 QUALITY EDUCATION | 5 GENDER EQUALITY | 6 CLEAN WATER AND SANITATION | 10 REDUCED INEQUALITIES | 17 PARTNERSHIPS FOR THE GOALS



© UNICEF Cambodia/2018/Chansereypich Seng

# ការការពារកុមារ

**ពុំមានកុមារណាម្នាក់ គួរទទួលរងអំពើហិង្សា ការរំលោភបំពាន និងការទុកចោលមិនអើពើនោះឡើយ។ កុមារី និងកុមារាដែលងាយរងគ្រោះ និងរងគ្រោះពីអំពើហិង្សា និងដែលត្រូវបានបំបែកចេញពីគ្រួសារ មានសិទ្ធិទទួលបានការការពារពីច្បាប់ សេវាសង្គម និងបរិយាកាសគាំទ្រនៅក្នុងសហគមន៍។**

កម្មវិធីការពារកុមារ ផ្តោតការយកចិត្តទុកដាក់លើការកសាងក្របខ័ណ្ឌច្បាប់កុមារមេត្រីដើម្បីផ្តល់ការការពារកុមារ និងក្មេងនៅកម្ពុជា តាមរយៈការដាក់ចេញនូវវិធានការទប់ស្កាត់ និងឆ្លើយតបចំពោះបទល្មើស និងលើកកម្ពស់ឱ្យមានការបង្កើតវប្បធម៌អហិង្សា តាមរយៈការផ្លាស់ប្តូរឥរិយាបថ និងជំនឿដែលបង្កឱ្យមានអំពើហិង្សាកើតមានឡើង នៅក្នុងសង្គម។

ការយកចិត្តទុកដាក់ត្រូវបានផ្តោតលើការពង្រឹងការការពារកុមារ ក្នុងវិស័យសុខាភិបាល អប់រំ យុត្តិធម៌ និងកុមារតូច។ ការងារទាំងនេះរួមមាន ការគាំទ្រដល់រដ្ឋាភិបាលក្នុងការរៀបចំច្បាប់ស្តីពីការការពារកុមារ និងការពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានការពារកុមារឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងការផ្តល់ការបណ្តុះបណ្តាលដល់ភ្នាក់ងារសង្គមកិច្ចស្តីពីសេវាសុខាភិបាល អប់រំ យុត្តិធម៌ និងការការពារកុមារ។

យូនីសេហ្វសហការជាមួយបណ្តាដៃគូនានា ដើម្បីផ្តល់ការបណ្តុះបណ្តាលដល់គ្រូ និងអ្នកដឹកនាំសាសនា ដើម្បីឱ្យពួកគេមានចំណេះដឹង និងការយល់ដឹងដែលពួកគេត្រូវការសម្រាប់ផ្តល់ការការពារដល់កុមារ។ យូនីសេហ្វរៀបចំយុទ្ធនាការដើម្បីធ្វើការផ្លាស់ប្តូរឥរិយាបថ និងការយល់ឃើញរបស់មនុស្សជុំវិញការដាក់វិន័យ ដែលនេះជាយន្តការផ្តោតលើការដាក់វិន័យបែបវិជ្ជមាន និងជំទាស់តតាំងនឹងការយល់ឃើញបច្ចុប្បន្នដែលបង្កឱ្យមានការបំបែកកុមារចេញពីគ្រួសាររបស់ពួកគេទាំងមិនចាំបាច់។

SUSTAINABLE DEVELOPMENT GOALS

4 QUALITY EDUCATION | 5 GENDER EQUALITY | 8 DECENT WORK AND ECONOMIC GROWTH | 10 REDUCED INEQUALITIES | 16 PEACE, JUSTICE AND STRONG INSTITUTIONS | 17 PARTNERSHIPS FOR THE GOALS


© UNICEF Cambodia/2017/Bona KHOY

# គោលនយោបាយ និង ហិរញ្ញប្បទានសាធារណៈដើម្បីកុមារ

ផលវិបាកនៃភាពក្រីក្រ អាចអូសបន្លាយពេញមួយជីវិត។ កុមារកម្រទទួលបានឱកាសទីពីរ ក្នុងការទទួលបានការអប់រំ ឬការចាប់ផ្តើមជីវិតប្រកបដោយសុខភាពល្អណាស់។ ខណៈពេលដែលភាពក្រីក្ររបស់កុមារបន្តគំរាមកំហែងដល់កុមារម្នាក់ៗ ប្រសិនបើពុំមានអន្តរាគមន៍ឱ្យបានគ្រប់គ្រាន់នោះទេ ភាពក្រីក្របែបនេះទំនងជានឹងផ្ទេរទៅជំនាន់ក្រោយៗទៀត ដែលនាំឱ្យវិសមភាពកាន់តែចាក់ឫសជ្រៅទៅៗនៅក្នុងសង្គម។

កម្មវិធីគោលនយោបាយ និងហិរញ្ញប្បទានសាធារណៈដើម្បីកុមារ ផ្តោតការយកចិត្តទុកដាក់លើការកាត់បន្ថយភាពក្រីក្រពហុសមាសភាគនៅកម្ពុជា ជាពិសេសកុមារដែលរស់នៅតាមតំបន់ក្រីក្រក្នុងទីប្រជុំជន និងជនបទ កុមារមកពីក្រុមជនជាតិភាគតិច និងកុមារដែលមានពិការភាព។ យូនីសេហ្វប្រើប្រាស់អភិក្រមពហុវិស័យ ដែលក្នុងនោះសកម្មភាពការពារកុមារត្រូវបានបញ្ចូលទៅក្នុងកម្មវិធីដទៃទៀត ដូចជាកម្មវិធីសុខភាព និងអាហារូបត្ថម្ភ អនាម័យ និងទឹកស្អាត អប់រំ និងការការពារកុមារជាដើម។

យូនីសេហ្វផ្តល់ការគាំទ្រដល់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ដើម្បីធានាយ៉ាងណាឱ្យកុមារ និងស្ត្រីនៅកម្ពុជាអាចទទួលបានកិច្ចគាំពារសង្គមដែលពួកគេត្រូវការ។ ដូចគ្នានេះដែរ យើងក៏ផ្តល់ការគាំទ្របច្ចេកទេសដល់ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីរៀបចំបញ្ចប់ និងអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការពិនិត្យតាមដាន និងវាយតម្លៃផងដែរ ក្នុងគោលបំណងឱ្យប្រព័ន្ធតាមដាន និងវាយតម្លៃរបស់ប្រទេសកម្ពុជាមានភាពរឹងមាំ និងអាចជឿទុកចិត្តបាន។ នៅក្នុងកិច្ចសហការនេះ ក៏នឹងមានការបន្តរៀបចំ អនុវត្ត និងតាមដានថវិកា សម្រាប់កម្មវិធីវិនិយោគលើវិស័យសង្គមដើម្បីឱ្យកម្មវិធីទាំងនេះមានភាពច្បាស់លាស់ និងអាចអនុវត្តទៅបានប្រកបដោយប្រសិទ្ធភាព។



# ជំហានបន្ទាប់

តាមរយៈការកសាងភាពជាដៃគូជាមួយរាជរដ្ឋាភិបាល សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល អ្នកផ្តល់ជំនួយ ស្ថាប័នសិក្សាស្រាវជ្រាវ វិស័យឯកជន ប្រព័ន្ធផ្សព្វផ្សាយ និងអាជ្ញាធរមូលដ្ឋាន យូនីសេហ្វនឹងប្រើប្រាស់ភាពជោគជ័យដែលសម្រេចបានកន្លងមកដើម្បីខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងការឈានទៅសម្រេចសិទ្ធិរបស់កុមារក្នុងប្រទេសកម្ពុជា។

ដើម្បីប្រែក្លាយចក្ខុវិស័យទៅជាសកម្មភាពជាក់ស្តែង យើងបានបញ្ចូលយុទ្ធសាស្ត្រដែលនាំមកនូវការផ្លាស់ប្តូរវិជ្ជមានមួយចំនួន ទៅក្នុងកម្មវិធីប្រចាំប្រទេស ២០១៩-២០២៣។ យុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រទាំងនេះ គឺការប្រើប្រាស់អភិក្រមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ពោលគឺអភិក្រមដែលចាត់ទុកការអប់រំ សុខភាពអនាម័យ អាហារូបត្ថម្ភថាជាកម្លាំងចលករដែលមិនអាចខ្វះបានសម្រាប់លើកកម្ពស់ការអភិវឌ្ឍកុមារតូច។

ដោយសម្លឹងទៅអនាគត ការយកចិត្តទុកដាក់របស់យើងនឹងផ្តោតកាន់តែខ្លាំងជាងមុនធ្វើយ៉ាងណាឱ្យគេអាចឮសំឡេងកុមារ និងក្មេងជំទង់ និងផ្តល់សេវាប្រកបដោយគុណភាព ងាយស្រួលទទួលបាន ប្រកបដោយសមធម៌ រាប់បញ្ចូលទាំងក្នុងសហគមន៍ដែលបាត់បង់ឱកាសផងដែរ។

យូនីសេហ្វនឹងគាំទ្រដល់ការប្រមូលភស្តុតាងដែលមានលក្ខណៈនវានុវត្តន៍ និងការប្រមូលការវិភាគ និងការប្រើប្រាស់ទិន្នន័យប្រកបដោយគុណភាព ដើម្បីផ្តល់ព័ត៌មានអំពីការផ្លាស់ប្តូរគោលនយោបាយ។ យើងធ្វើការងារនៅច្រើនកម្រិត ដូចជាថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសហគមន៍ ដើម្បីធានាថាសកម្មភាពរបស់យើងមានលក្ខណៈបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក និងអាចឈានទៅសម្រេចលទ្ធផលជាអតិបរមា។

តាមរយៈការលើកកម្ពស់ ការសម្របសម្រួល និងការពិនិត្យតាមដាន និងការរៀបចំផែនការជាយុទ្ធសាស្ត្រ ដើម្បីពង្រីកការអនុវត្តកម្មវិធីយើងគឺជាស្ថាប័នដែលត្រៀមលក្ខណៈរួចជាស្រេច ដើម្បីកៀរគរធនធានឱ្យបានច្រើនបំផុតឱ្យដល់កុមារម្នាក់ៗ។តាមរយៈការផ្ទេរជំនាញ និងការចែករំលែកចំណេះដឹង យើងត្រួសត្រាយផ្លូវ ដើម្បីឱ្យមានការផ្តល់សេវាសុខភាព អាហារូបត្ថម្ភ អនាម័យ និងស្អាត ការការពារកុមារ និងការអប់រំប្រកបដោយនិរន្តរភាព។

រាល់កម្មវិធីទាំងអស់របស់យូនីសេហ្វ សុទ្ធតែបានបញ្ចូលសកម្មភាពពង្រឹងភាពធន់របស់កុមារ គ្រួសារ និងសហគមន៍ ដូចជាការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការត្រៀមបង្ការស្ថានភាពអាសន្នជាដើម។ អភិក្រមផ្តោតលើយេនឌ័រ និងគិតគូរពីតម្រូវការរបស់ក្មេងជំទង់នឹងត្រូវអនុវត្ត ដើម្បីឆ្លើយតបចំពោះឧបសគ្គនានា ដែលរារាំងកុមារី និងកុមារា ពុំអាចសម្រេចបានសិទ្ធិរបស់ពួកគេ។

ថវិកាដែលត្រូវបានស្នើឡើងសម្រាប់អនុវត្តកម្មវិធីប្រចាំប្រទេស ២០១៩-២០២៣ គឺ ១២១.៦៥៦.០០០ដុល្លារ។ យូនីសេហ្វនៅកម្ពុជា ទទួលបានការគាំទ្រពីការរួមវិភាគទានប្រកបដោយភាពសប្បុរស ពីបណ្តាញគណៈកម្មាធិការជាតិរបស់យូនីសេហ្វ រដ្ឋាភិបាល និងសប្បុរសជន និងអ្នកផ្តល់ជំនួយវិស័យឯកជន។

unicef | for every child


## យូនីសេហ្វកម្ពុជា

អគារ Exchange Square លេខ១៩&២០ ជាន់ទី៥ ផ្លូវលេខ១០៦
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរសព្ទ៖ +៨៥៥ ២៣ ២៦០ ២០៤

ទូរសារ៖ +៨៥៥ ២៣ ៤២៦ ២៨៤

អ៊ីម៉ែល៖ phnompenh@unicef.org

វេបសាយ៖ www.unicef.org.kh


facebook.com/unicefcambodia twitter.com/unicefcambodia youtube.com/unicefcambodia @unicefcambodia